

# ដួងកែវចង់ក្លាយជាអ្នកលេងសៀក

Fongsamay Phommaxay

Lý Minh Phúc

Let's Read

The Asia Foundation



ដួងកែវស្រែក "សួស្តី សម្លាញ់ទាំងអស់គ្នា!"
ឈ្មោះរបស់ពួកគេគឺ រដ្ឋា កូលាប និងសុវណ្ណ។



កូលាបចង់ក្លាយជាគ្រូបង្រៀនពូកែម្នាក់។ នាងចូលចិត្តជួយបង្រៀនអ្នកដទៃ។



រដ្ឋាចង់ក្លាយជាវេជ្ជបណ្ឌិត ព្រោះនាងចង់ជួយព្យាបាលអ្នកជំងឺ។



សុវណ្ណចង់ក្លាយជាភិក្ខុសង្ឃ។ គាត់ចង់បង្រៀនមនុស្សក្នុង
សហគមន៍ឱ្យប្រតិបត្តិសេចក្តីល្អជាប្រចាំ។



ចំណែកដួងកែវវិញ នាងចង់ក្លាយជាអ្នកលេងសៀករហស្សកម្ម ព្រោះនាងចូលចិត្តការសម្ដែងសៀកណាស់!



ដួងកែវមិនដឹងធ្វើយ៉ាងណាដើម្បីក្លាយជាអ្នកលេងសៀក។ នាងគ្មានសម្ភារៈដូចអ្នកលេងសៀកផង។ ម្យ៉ាងទៀត នៅកន្លែងដែលនាងរស់នៅ ក៏មិនមានសាលាសម្រាប់បង្រៀនសៀកដែរ។



ដួងកែវស្រឡាញ់ប៉ូប៉ូណាស់។ ប៉ូប៉ូគឺជាឆ្កែរបស់នាង។



បូបូពូកែណាស់ និងចេះសម្តែងទៀតផង។



ភាពពូកែនិងការសម្តែងរបស់បូបូធ្វើឱ្យដួងកែវមានគំនិតមួយ។



ដួងកែវចាប់ផ្តើមលេងសៀកដោយខ្លួនឯង ហើយបូបូនឹងជួយ
ដួងកែវក្នុងការសម្តែង។



ដំបូង ដួងកែវប្រែល្អីដាក់អង្ករ ទៅជាម្ជូកវេទមន្ត។



បន្ទាប់មក នាងប្រែផ្ទាំងវាំងនន ទៅជាអាវវេទមន្ត។



ស្នុគបាយដំណើប ប្រែជាប្រអប់វេទមន្ត។



ចង្កឹះ ប្រែជាដំបងវេទមន្ត។



ទីបំផុត ដួងកែវក្លាយជាអ្នកលេងសៀកដ៏ពូកែម្នាក់! ឥឡូវនេះ នាង និងកូនឆ្កែរបស់នាងអាចសម្តែងសៀកឱ្យមិត្តភក្តិមើល ហើយ។



ការសម្តែងសៀករបស់ដួងកែវនិងបូបូចាប់ផ្តើមហើយ។

ចំណងជើងនេះទទួលបានការអនុម័តឱ្យប្រើប្រាស់ដោយ ក្រសួងអប់រំ យុវជន និងកីឡា

Endorsed by:
The Ministry of Education, Youth, and Sport, Cambodia

គាំទ្រដោយ៖
Supported by:

Brought to you by

The Asia Foundation

Let’s Read is an initiative of The Asia Foundation’s Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**
*Douangkeo Wants to Be a Magician*, Illustrator: Lý Minh Phúc. Published by Room to Read, © Room to Read. Released under CC BY 4.0.

This work is a modified version of the original story. © The Asia Foundation, 2020. Some rights reserved. Released under CC BY 4.0.

For full terms of use and attribution, http://creativecommons.org/licenses/by/4.0/
Contributing translators: Somey Chheang and Prum Kunthearo